ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣ សហវ.ស៊ា

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៦

# សេចក្តីណែនាំ
# ស្តីពី
# សោហ៊ុយលើសេវាសំណង់

ដោយអនុក្រឹត្យលេខ ៨៦ អនក្រ. បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតិសាងសង់ពុំមានកំណត់តំលៃនៃសេវាសំណង់នៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញប្រកាសអន្តរក្រសួងស្តីពីសោហ៊ុយលើសេវាសំណង់ដើម្បីប្រមូលចំណូលមិនមែនសារពើពន្ធស្របតាមច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

ដើម្បីកុំឱ្យការអនុវត្តមានការខុសឆ្គង ដោយបកស្រាយខុសពីខ្លឹមសារនៃអង្គប្រជុំអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវលើប្រការមួយចំនួន នៃប្រកាសអន្តរក្រសួងលេខ ០៣៣ សហវ.ប្រក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៦ នេះ ដូចខាងក្រោម :

ទី១ -ពេលចុះបេសកកម្មមន្ត្រីជំនាញត្រូវគោរពក្រមសីលធម៌ វិជ្ជាជីវៈ និងច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលពោល គឺ មិនត្រូវទាមទារពីម្ចាស់សំណង់នូវសោហ៊ុយហូបចុក ស្នាក់នៅ ហួសពីកំរិតប្រហាក់ប្រហែល ដែលមានចែងក្នុងអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របប បេសកកម្មក្នុង និងក្រៅប្រទេស ។

ទី២ -ពេលបានការជួយឧបត្ថម្ភ នូវសោហ៊ុយបេសកកម្មក្នុងការហូបចុក ស្នាក់នៅ ពីម្ចាស់សំណង់រួចហើយមិនត្រូវទាមទាររបបឧបត្ថម្ភ បន្ថែមពីរដ្ឋទៀតឡើយ ។

ទី៣ -រាល់ទំរង់បែបបទ និង សំណុំឯកសារ ពាក់ពន្ធ័នឹងការសុំ និង ការផ្តល់អាជ្ញាបណ្ណ័ សាងសង់ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា១៨របស់អនុក្រឹត្យលេខ៨៦ អនក្រ.ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលបានកំណត់ត្រឹម៤៥ ថ្ងៃធ្វើការដោយគិតពីថ្ងៃបានបំពេញសព្វគ្រប់នូវរាល់លិខិតស្នាមដែលត្រូវភ្ជាប់ជាមួយពាក្យសុំលិខិតអនុញ្ញាតសាងសង់ដើម្បីជៀសវាងការអូសបន្លាយពេលវេលាដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ម្ចាស់សំណង់ ។

ទី៤ -ប្រកាសនេះបានកំណត់ អប្បហារជាផ្លូវការជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់រួចហើយ ដូច្នេះមិនត្រូវទាមទារបន្ថែមកំរៃ ក្រៅពីសោហ៊ុយសេវាសំណង់ដែលមាននៅក្នុងបង្កាន់ដៃឡើយ ។

ទី៥ -ដើម្បីឱ្យមានតម្លាភាព សោហ៊ុយសេវាសំណង់នេះ ត្រូវបានផ្សព្វផ្សាយ ជាសាធារណៈ ឱ្យបានទូលំទូលាយ ព្រមទាំងមានបិទផ្សព្វផ្សាយ នៅគ្រប់អង្គភាព ដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ។

ទី៦ -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងចាត់បញ្ជូនមន្ត្រីជំនាញរបស់នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ចុះតាមដានត្រួតពិនិត្យ ជាប្រចាំដើម្បីធានាការអនុវត្តប្រកាសនេះប្រកបដោយសមធម៌ ត្រឹមត្រូវតាមច្បាប់ និងធានាបាននូវតុល្យភាពរវាងផលប្រយោជន៍រដ្ឋ និង ផលប្រយោជន៍ប្រជាពលរដ្ឋជាម្ចាស់សំណង់ ។

ទី៧ -ក្នុងករណីពិនិត្យឃើញថា ការអនុវត្តប្រកាសអន្តរក្រសួង ស្តីពីសោហ៊ុយលើសេវាសំណង់មានបញ្ហារាំងស្ទះឬបង្កការលំបាកដល់ម្ចាស់សំណង់ហួសហេតុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចូលរួមរៀបចំធ្វើការកែតំរូវប្រកាសនេះជាថ្មីឱ្យបានសមហេតុសមផលវិញ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

<u>កន្លែងទទួល:</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
  " ដើម្បីមុខការ និង ផ្សព្វផ្សាយដល់អង្គភាពក្រោមឱវាទ "
- អភិបាល ខេត្ត ក្រុង
  " ដើម្បីជ្រាបជាពតិមាន "
- ឯកសារ-កាលប្បវត្តិ